**SAMPLE**

## សំនួរដែលមាតាបិតាតែងតែសួរជាញឹកញាប់អំពីប័ណ្ណរបាយការណ៍សិក្សា
## Questions Parents Frequently Ask About District Report Cards

**ស. 1 កាលពីខែមេសា ឆ្នាំកន្លងទៅ យើងបានទទួលប័ណ្ណរបាយការណ៍សិក្សាដូចគ្នានឹងប័ណ្ណមួយនេះ ។ តើប័ណ្ណរបាយការណ៍សិក្សានេះខុសប្លែកពីគ្នារបៀបណា?**

**ឆ. 1** ដោយឡែកពីការផ្តល់បច្ចុប្បន្នភាពនៃពិន្ទុប្រឡង និងទិន្នន័យគ្រូបង្រៀនថ្មី ប័ណ្ណរបាយការណ៍សិក្សាឆ្នាំនេះមានបញ្ចូលពត៌មានច្រើនគួរសមជាងឆ្នាំទៅ ។ ជាពិសេសប័ណ្ណរបាយការណ៍សិក្សាឆ្នាំនេះផ្តល់ការកំណត់ AYP សំរាប់អនុក្រុមរបស់សិស្សមួយរូបៗនៅក្នុងសាលារបស់យើង មិនមែនសំរាប់សាលាទាំងអស់ទាំងស្រុងនោះទេ ។ ប័ណ្ណថ្មីនេះបង្ហាញនូវវិធានការណ៍ថ្មី លិបិក្រមនៃសមាសធាតុលទ្ធផល (Composite Performance Index) ដែលមានរួមបញ្ចូលនូវពិន្ទុរបស់សិស្សមានពិការភាពដែលចូលរួមនៅក្នុងកម្មវិធីនៃការប៉ាន់ប្រមាណរបៀបឆ្លាស់នៃ MCAS (MCAS Alternate Assessment program) ។ ការប្រើវិធានការណ៍បន្ថែម—ការមករៀនរបស់សិស្ស និងកំរិតបញ្ចប់ការសិក្សា – ដើម្បីកំណត់មើលថា តើសាលាមានធ្វើឲ្យមានការលូតលាស់ប្រចាំឆ្នាំគ្រប់គ្រាន់ ឬទេ ។ ហើយវាទាញចេញមកពីទិន្នន័យគុណភាពគ្រូបង្រៀនពីឯកសារទិន្នន័យដែលបានប្រមូលជាទូទៅក្នុងរដ្ឋកាលពីខែធ្នូ ឆ្នាំ 2003 ។

កាលពីឆ្នាំទៅក្រសួងអប់រំបាននៅតែកែតំរូវឡើងវិញនូវប្រព័ន្ធកំរិតលទ្ធផលសាលាដើម្បីសម្រួលទៅតាមសេចក្តីតំរូវការថ្មីរបស់សហព័ន្ធ ។ ការនេះបណ្តាលជាលទ្ធផលឲ្យមានរបាយការណ៍លើការកំណត់ AYP សំរាប់សាលាតែប៉ុណ្ណោះ ហើយមិនមែនសំរាប់អនុក្រុមសិស្សានុសិស្សទេ ។ ក្រសួងក៏មិនមានប្រព័ន្ធបច្ចេកទេសនៅនឹងកន្លែងដើម្បីប្រមូលយកទិន្នន័យគ្រូបង្រៀននៅក្នុងកំរិតច្រើននោះដែរ ដូច្នេះហើយគេត្រូវតែពឹងផ្អែកទៅលើវិធានការណ៍មិនចំពោះអំពីគុណភាពរបស់គ្រូបង្រៀនទូទាំងប្រទេស ។ ឆ្នាំនេះទិន្នន័យគុណភាពគ្រូបង្រៀននឹងត្រូវផ្ញើមកពីសាលា និងមណ្ឌលសិក្សាដោយផ្ទាល់ ហើយផ្ញើពីមណ្ឌលសិក្សាទៅរដ្ឋទាំងមូល ដោយប្រើទ្រង់ទ្រាយសាមញ្ញធម្មតា ។ ទ្រង់ទ្រាយថ្មីនេះនឹងធ្វើឲ្យមាតាបិតាមានការងាយស្រួលធ្វើការប្រៀបធៀបទិន្នន័យគុណភាពគ្រូបង្រៀននៅតាមសាលារបស់គេជាមួយសាលាឯទៀតនៅក្នុងមណ្ឌលសិក្សា ។

**ស. 2 ជំពូកអំពីលក្ខណសម្បត្តិរបស់គ្រូបង្រៀនទាញបង្ហាញនូវការខុសគ្នារវាងភាព “មានវិញ្ញាបនប័ត្រ” និង “មានគុណវុឌ្ឍិខ្ពស់” តើអ្វីទៅដែលជាលក្ខណសំខាន់នៃភាពខុសគ្នានេះ?**

**ឆ. 2 ភាពមានវិញ្ញាបនប័ត្រគរុកោសល្យ និងភាពមាន “មានគុណវុឌ្ឍិខ្ពស់” ក្នុងការបង្រៀនគឺជាកំរិតពីរខុសគ្នា ដែលប្រើសំរាប់ពិពណ៌នាជីវប្រវត្តិ និងការរៀបចំកិច្ចការគរុកោសល្យនៅក្នុងមណ្ឌលសិក្សា ។ វិញ្ញាបនប័ត្រថែងថាតើគ្រូបង្រៀននោះជួបតាមសេចក្តីតំរូវរបស់រដ្ឋ Massachusetts សំរាប់អាជ្ញាប័ណ្ណគរុកោសល្យ ឬទេ ។ “មានគុណវុឌ្ឍិខ្ពស់” សួរថាតើគ្រូបង្រៀនមានអាជ្ញាប័ណ្ណរដ្ឋ Massachusetts ហើយតើមានបង្ហាញនូវសមត្ថភាពនៃប្រធានបទផ្នែកមុខវិជ្ជាដែលអ្នកនោះបង្រៀន ឬទេ ។**

**ដោយសាររដ្ឋ Massachusetts មានបទដ្ឋានខ្ពស់មួយចំនួនសំរាប់ចេញអាជ្ញាប័ណ្ណគរុកោសល្យនៅក្នុងប្រទេស ស្ទើរតែគ្រប់គ្រូបង្រៀនភាគច្រើននៅក្នុងមណ្ឌលសិក្សារបស់យើង គឺសុទ្ធតែជាអ្នកត្រូវបានចេញវិញ្ញាបនប័ត្រ ហើយ ស្ទើរតែគ្រប់គ្រូបង្រៀនភាគច្រើន គឺមានគុណវុឌ្ឍិខ្ពស់ ។ ចំពោះគ្រូដែលមិនទាន់ត្រូវបានចេញវិញ្ញាបនប័ត្រ នៅឡើយនោះគឺកំពុងធ្វើការសុំអនុគ្រោះដែលត្រូវយល់ព្រមដោយក្រសួងសិក្សាធិការរដ្ឋ Massachusetts ឬកំពុងធ្វើជាគ្រូបង្រៀន**

ជំនួសពេលយូរ ឬក៏ជំនួសជាអចិន្ត្រៃ ។ ចំពោះគ្រូទាំងឡាយដែលមិនទាន់មានបង្ហាញសមត្ថភាពនៃប្រធានបទនៅឡើយនោះ ឥឡូវនេះគឺនៅក្នុងដំណើរការសិក្សាមេរៀនបន្ថែមដើម្បីឲ្យជួបតាមតំរូវការពីសហព័ន្ធ ។ អ្វីដែលអ្នកនឹងឃើញនៅក្នុងភាគរយបង្ហាញនៅក្នុងប័ណ្ណរបាយការណ៏សិក្សាគឺជាការចង្អុលបង្ហាញថាតើនៅរយៈពេលប៉ុណ្ណាទៀតដែលមណ្ឌលសិក្សា និងសាលារៀនរបស់យើងត្រូវតែធ្វើដើម្បីឲ្យជួបតាមកាលបរិច្ឆេទកំណត់នេះ ។

**ស. 3 តើខ្ញុំអាចដឹងដោយរបៀបណា ថាតើគ្រូបង្រៀនកូនរបស់ខ្ញុំជាគ្រូមានគុណវុឌ្ឍិខ្ពស់?**

**ឆ. 3** ស្ថិតិអំពីគ្រូបង្រៀនដែលមានគុណវុឌ្ឍិខ្ពស់ផ្តល់ជូនមាតាបិតាសិស្សនូវការសង្កេតដោយឡែកអំពីការរៀបចំរបស់បុគ្គលិកនៃសាលានិមួយៗ ដើម្បីបង្រៀនប្រធានបទសំខាន់ៗនោះឲ្យមានប្រសិទ្ធិភាព ។ ពត៏មាននេះផ្តល់ជូននូវទម្រង់ (profile) ជាក្រុម ។ ពត៏មាននោះមិនមែនមានន័យថាចុចយកគ្រូបង្រៀនដោយឈ្មោះ ឬដោយកំរិតថ្នាក់បង្រៀននោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ បើមាតាបិតាចង់ដឹងថា តើគ្រូបង្រៀនកូនរបស់គេជួបតាមបទដ្ឋាន "មានគុណវុឌ្ឍិខ្ពស់" គេអាចសុំឲ្យលោកអធិការកិច្ចមណ្ឌលសិក្សាឲ្យផ្តល់នូវពត៏មានដូចខាងក្រោមនេះ: (1) តើគ្រូបង្រៀននោះមានសញ្ញាប័ត្រកំរិតណា (2) តើគាត់មានវិញ្ញាបនប័ត្រអ្វីខ្លះ (3) តើលោកគ្រូ-អ្នកគ្រូនោះជួបតាមអត្ថន័យដែលមានតំរូវសំរាប់គ្រូបង្រៀនដែលបង្រៀននៅមុខវិជ្ជាសំខាន់ៗនោះឬទេ ។ គ្រូបង្រៀនទាំងអស់ដែលបានជួល <u>ក្រោយ</u> ពីថ្ងៃទី 8 ខែមករា ឆ្នាំ 2002 ត្រូវតែមាន គុណវុឌ្ឍិខ្ពស់មុនពេលចាប់ផ្តើមធ្វើការ ។ គ្រូបង្រៀនទាំងអស់ដែលកំពុងធ្វើការនៅក្នុងសាលារៀនរបស់អ្នកមុន ថ្ងៃទី 8 ខែមករា ឆ្នាំ 2002 ត្រូវតែមានគុណវុឌ្ឍិខ្ពស់ឲ្យបាននៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2006 ។

**ស. 4 តើខ្ញុំត្រូវធ្វើយ៉ាងណា បើគ្រូបង្រៀនកូនរបស់ខ្ញុំមិនមែនជាគ្រូមានគុណវុឌ្ឍិខ្ពស់នោះ?**

**ឆ. 4** ច្បាប់អំពី *គ្មានកុមារណាម្នាក់ត្រូវគេទុកចោលពីក្រោយ* តំរូវថាគ្រប់គ្រូបង្រៀនទាំងអស់ដែលបង្រៀនមុខវិជ្ជាសំខាន់ៗត្រូវតែ "មានគុណវុឌ្ឍិខ្ពស់" ឲ្យបាននៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2006 ។ ក្រោយពីនោះមក គ្រូបង្រៀនរបស់កូនអ្នកអាចនៅក្នុងដំណើរការឲ្យក្លាយទៅទៅគ្រូមានគុណវុឌ្ឍិខ្ពស់ដូចបានចែងនៅក្នុងច្បាប់ ទោះជាអ្នកធ្លាប់មានជោគជ័យក្នុងការបង្រៀនជាយូរឆ្នាំមកហើយក៏ដោយ ។ បើសិនជាការនេះនឹងកើតមាន អ្នកអាចសួរឲ្យដឹងនូវវិធានការណ៏អ្វីដែលសាលារបស់អ្នកបានធ្វើដើម្បីធានាថា គ្រប់គ្រូបង្រៀនទាំងអស់នឹងមានគុណវុឌ្ឍិខ្ពស់ឲ្យបាននៅឆ្នាំ 2006 ។ សាលារៀននិមួយៗត្រូវតែមានផែនការនៅនឹងកន្លែងដើម្បីធានាថាបុគ្គលិកបង្រៀនរបស់គេមានគុណវុឌ្ឍិខ្ពស់ ។ វាអាចជាមានសភាពការខ្វះៗ តែទោះជាយ៉ាងណាក៏ដោយ បើសិនជាសាលាមិនអាចជួលគ្រូបង្រៀនមានគុណវុឌ្ឍិខ្ពស់នៅក្នុងប្រធានបទដោយសារតែគ្មានគ្រូបង្រៀនគ្រប់គ្រាន់ ។ កាលៈទេសៈនេះ *នឹងមិន* ធ្វើឲ្យអ្នកអាចស្នើសុំគ្រូមកពីកន្លែងផ្សេងទៀត ឬផ្លាស់ទៅរៀនសាលាដ៏ទៃបានទេ ក៏ប៉ុន្តែគេជំរុញឲ្យអ្នកធ្វើការជាមួយអ្នកគ្រប់គ្រងសាលាក្នុងការជួយជ្រើសរើសរកគ្រូមានគុណវុឌ្ឍិខ្ពស់សំរាប់សាលាអ្នក ។

**ស. 5 តើមានន័យយ៉ាងណា បើសាលារៀនរបស់ខ្ញុំត្រូវបានគេចាត់ទុកថាជាសាលា "ត្រូវការសេចក្តីចំរើនល្វតលាស់?"**

**ឆ. 5** គ្រប់សាលាទាំងអស់នៅក្នុងសហរដ្ឋអាមេរិកត្រូវបានតំរូវឲ្យធានាថាគ្រប់សិស្សានុសិស្សទាំងអស់គឺ "ជំនាញ" ក្នុងការអាននិងគណិតសាស្រ្តនៅឆ្នាំ 2014 ។ ដើម្បីឲ្យជួបតាមគោលបំណងនេះ សាលារំពឹងថាការបំពេញមុខងារនឹងអាចជួបតាមចំណុចទិសដៅមួយចំនួនផ្នែកការអាន និងគណិតសាស្រ្តក្នុងឆ្នាំនិមួយៗ ។ ចំណុចទិសដៅសំរាប់ការបំពេញការងារក៏ត្រូវបានរៀបចំឡើងសំរាប់អនុក្រុមផ្សេងៗគ្នានៅក្នុងសាលា (អាហ្វ្រិកាំង-អាមេរិកាំង ហ៊ីស្ប៉ានិក សិស្សមានពិការភាព សិស្សដែលមិនសូវចេះនិយាយភាសាអង់គ្លេស ជាដើម ។ល។) សាលាដែលនៅក្នុងស្ថានភាព ត្រូវការឲ្យមានការចំរើន

**SAMPLE**

លូតលាស់ គឺសាលាដែលមិនបានធ្វើឲ្យមានការ "ការចំរើនលូតលាស់ប្រចាំឆ្នាំគ្រប់គ្រាន" (AYP) រវាងពី ពីរ ឬបីឆ្នាំជាប់ៗគ្នាផ្នែកគណិតសាស្ត្រ ឬផ្នែកការអាន ។ សាលាដែលនៅក្នុងស្ថានភាពត្រូវការឲ្យមានការចំរើនលូតលាស់ក៏ជាសាលាដែលមិនបានធ្វើឲ្យមានការលូតលាស់ AYP សំរាប់អនុក្រុមណាមួយក្នុងរវាងពីរឆ្នាំជាប់ៗគ្នា ។

**ស. 6 តើ "ការចំរើនលូតលាស់ប្រចាំឆ្នាំគ្រប់គ្រាន់" (AYP) ពឹងផ្អែកតែទៅលើកិច្ចការសិក្សារបស់សាលាប៉ុណ្ណោះទេឬ?**

**ឆ. 6** ទេ ។ ជាបន្ថែមទៅលើការជួបតាមការរំពឹងនៃកិច្ចសិក្សាផ្នែកការអាន និងផ្នែកគណិតសាស្ត្រ សាលាត្រូវតែជួបតាមការតំរូវមួយចំនួនថែមទៀតជារៀងរាល់ឆ្នាំ បើសិនជាគេត្រូវធ្វើ AYP ។ ជាឧទាហរណ៏ ជាការមិនគ្រប់គ្រាន់ទេ ដែលសិស្សបានឈានសម្រេចទៅដល់រង្វង់គោលដៅប្រចាំឆ្នាំនិមួយៗតែផ្នែកការអាន និងគណិតសាស្ត្រនោះ ។ យ៉ាងហោចណាស់ **95%** នៃសិស្សទាំងអស់ត្រូវតែធ្វើការប្រឡងជារៀងរាល់ឆ្នាំ ហើយបើសិនជាចំនួនកូនសិស្សនោះធ្លាក់ក្រោម 95%, ពេលនោះគេអាចប្រកាសសាលានោះថាមិនបានជួបតាមកំរិត AYP ។ នៅក្នុងស្ថានភាពនេះចំនួនសិស្សដែលចូលរួមធ្វើការប្រឡងមានកំរិតទាបអាចបណ្តាលឲ្យសាលានោះមិនជួបតាម AYP បានដែរ ។

សាលាទាំងឡាយអាចចាត់ទុកថាមិនមានជួបតាម AYP បើសិនជាវត្តមានសិក្សារបស់សិស្សមានកំរិតទាបពេក ឬបើសិនជាគេបានបញ្ចប់ការសិក្សាពីវិទ្យាល័យតិចពេក ។ វត្តមានសិក្សា ជាពិសេសគឺជាផ្នែកមួយមានសារៈសំខាន់ខ្លាំងណាស់ ដែលជាញយៗគឺជាមូលហេតុចំបងដែលថា សិស្សមានជោគជ័យ ឬរៀនសូត្រមិនបានល្អនៅសាលា ។ ជាមួយនឹងច្បាប់ NCLB ទោះជាយ៉ាងណាក៏ដោយ វត្តមានសិក្សាគឺជាកត្តាមានសារៈសំខាន់ដូចកត្តាបីទៀតដូច្នេះដែរ ។

ជាសង្ខេប AYP គឺយោលទៅលើកត្តាបួនយ៉ាងៈ ការចូលរួមក្នុងការប្រឡង វត្តមានសិក្សារបស់សិស្ស កំរិតនៃការបញ្ចប់ការសិក្សា *និង* ការសិក្សាទូទៅ ។

**ស. 7 តើខ្ញុំត្រូវធ្វើដូចម្តេច បើសិនជាសាលារៀនរបស់ខ្ញុំត្រូវបានប្រកាសថា "ត្រូវការឲ្យមានការចំរើនលូតលាស់?"**

**ឆ. 7** នៅពេលដែលសាលាមិនទាន់ធ្វើ AYP បានក្នុងរវាង ពីរ ឆ្នាំជាប់ៗគ្នា មាតាបិតាមានសិទ្ធិបញ្ជូនកូនរបស់គេទៅរៀននៅសាលាផ្សេងទៀតនៅក្នុងមណ្ឌលសិក្សាដូចគ្នាដែលបានធ្វើឲ្យមានការរីកចំរើនប្រចាំឆ្នាំគ្រប់គ្រាន់ ។ សិទ្ធិជ្រើសរើសសាលារៀនថ្មីក្នុងមណ្ឌលសិក្សាគឺជាសិទ្ធិដែលត្រូវបានធានាដោយច្បាប NCLB ។ មាតាបិតាដែលចង់ប្រើសិទ្ធិ "ជ្រើសរើស" គួរតែទាក់ទងមកភ្នាក់ងារសាលារៀនដើម្បីឲ្យដឹងនូវអ្វីដែលគេចង់ធ្វើក្នុងការបញ្ជូនកូនរបស់គេទៅសាលារៀនថ្មី ។

សាលារៀនដែលមិនទាន់បានធ្វើឲ្យមានការរីកចំរើនប្រចាំឆ្នាំគ្រប់គ្រាន់ (AYP) ក្នុងរវាង បីឆ្នាំជាប់ៗគ្នា—ជាបន្ថែមពីលើការផ្តល់ឲ្យមាតាបិតានូវសិទ្ធិជ្រើសរើសសាលារៀនថ្មី—ត្រូវតែផ្តល់ឲ្យមាតាបិតាមានឱកាសទទួល "សេវាអប់រំបន្ថែម" សំរាប់កូនរបស់គេ ។ សេវាបន្ថែម– ដូចជាការបង្រៀនមួយទល់មួយ–គឺមានគោលបំណងផ្តល់ឲ្យសិស្សនូវការជួយបន្ថែមដើម្បីឲ្យមានការស្ទាត់ជំនាញលើវិជ្ជាជាមូលដ្ឋាន និងដើម្បីរៀនឲ្យទាន់គេ ។ ការជួយបន្ថែមអាចផ្តល់ជូនក្រោយពីម៉ោងសាលា នៅថ្ងៃដំណាច់សប្តាហ៏ ឬនៅពេលសាលាវិស្សមកាល ។ មាតាបិតាដែលចង់បានសេវាបន្ថែមនេះគួរតែទាក់ទងមកភ្នាក់ងារតាមសាលារបស់គេដើម្បីឲ្យដឹងថាតើកម្មវិធីអ្វីខ្លះដែលមាន ហើយតើនៅសាលាណាដែលគេត្រូវបញ្ជូនកូនរបស់គេទៅសិក្សា ។

**SAMPLE**

**ស. 8 តើមានន័យយ៉ាងណា បើសាលារៀនរបស់ខ្ញុំត្រូវតែធ្វើ “សកម្មភាពកែតំរូវ” ដើម្បីកែលំអសិស្សឲ្យកាន់តែមានជោគជ័យល្អ?**

**ឆ. 8** សាលាដែលត្រូវការឲ្យមាន “សកម្មភាពកែតំរូវ” គឺសាលាដែលមិនបានធ្វើឲ្យមាន AYP ក្នុងរយៈពេល បួន ឆ្នាំជាប់ៗគ្នា សំរាប់មូលហេតុដែលបានពិភាក្សាខាងលើ ។ អ្វីដែលឲ្យនិយមន័យអំពី “សកម្មភាពកែតំរូវ” គឺសាលានោះត្រូវចាត់វិធានការណ៏ឲ្យលើសពី “ការជ្រើសរើស” ហើយនិង “សេវាបន្ថែម”ដើម្បីបំបែករយៈវេលានៃបរាជ័យ ហើយធ្វើឲ្យមានការចំរើនលូតលាស់ប្រចាំឆ្នាំគ្រប់គ្រាន់ ។ វិធានការណ៏នេះអាចមានរួមនូវការផ្លាស់ប្តូរកម្មវិធីសិក្សា កាលវិភាគ ឬវិន័យសំរាប់សិស្ស ។ វិធានការណ៏នេះអាចមានរួមនូវការរៀបចំជាថ្មីនូវការដឹកនាំនៅសាលាដោយការជួលសិក្សាភិរក្សថ្មីឡើងវិញ ឬបុគ្គលិកសំខាន់ៗណាម្នាក់ ។ មាតាបិតានៅក្នុងសាលាដែលត្រូវបានចាត់ទុកថាត្រូវការសកម្មភាពកែតំរូវ គឺត្រូវបានជំរុញឲ្យសួរនាំអំពីវិធានការណ៏ដែលមណ្ឌលសិក្សាត្រូវធ្វើបន្ទាប់ៗទៀត ។ សាលាដែលនៅក្នុង “សកម្មភាពកែតំរូវ” ត្រូវតែអនុញ្ញាតឲ្យមាតាបិតាមានសិទ្ធិជ្រើសរើសសាលាផ្សេងទៀត ឬទទួលសេវាអប់រំបន្ថែម ។

**ស. 9 តើខ្ញុំអាចទទួលពត៏មានថែមទៀតអំពីប័ណ្ណរបាយការណ៏សិក្សានៅឯណា?**

**ឆ. 9** មាតាបិតាដែលចង់ដឹងពត៏មានថែមទៀតពីប័ណ្ណរបាយការណ៏សិក្សា សូមមេត្តាទាក់ទងជាមួយសិក្សាភិរក្សសាលារបស់គេ ពិនិត្យប្រព័ន្ធវិបសាយរបស់សហព័ន្ធអំពី *No Child Left Behind* នៅអាស័យដ្ឋាន: www.ed.gov/parents/academic/involve/nclbguide/parentsguide.pdf. ឬពិនិត្យពត៏មានអំពីប័ណ្ណរបាយការណ៏សិក្សានៅតាមប្រព័ន្ធវិបសាយរបស់ក្រសួងសិក្សាធិការ www.doe.mass.edu/nclb/reportcard/default.html.